**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៩៧ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ការគ្រប់គ្រង និងការប្រើប្រាស់ដីចំណីតាមបណ្តោយផ្លូវជាតិនិងផ្លូវរថភ្លើង ឱ្យសមស្របតាមការអភិវឌ្ឍ និងការរីកចម្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណង៖

- លុបបំបាត់បាតុភាពទន្រ្ទានយកដីចំណីទៅធ្វើការសាងសង់សំណង់ ឬដាំដំណាំផ្សេងៗ
- ទប់ស្កាត់ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍និងរក្សាសណ្តាប់ធ្នាប់សង្គមដែលតែងកើតមាននៅតាមបណ្តោយផ្លូវ
- កាត់បន្ថយឧបសគ្គនានាដែលរាំងស្ទះដល់ការអភិវឌ្ឍផ្លូវ
- កាត់បន្ថយរាល់ការចំណាយរបស់រដ្ឋលើការដោះស្រាយផលប៉ះពាល់ផ្ទះសម្បែងប្រជាពលរដ្ឋដែលតាំងនៅតាមបណ្តោយផ្លូវ
- បង្កលក្ខណៈងាយស្រួលដល់សមត្ថកិច្ចពាក់ព័ន្ធក្នុងការផ្តល់ភាពស្របច្បាប់ដល់ប្រជាពលរដ្ឋដែលមានកម្មសិទ្ធិនៅតាមបណ្តោយផ្លូវ
- ធានាការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរបវន្តប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់ទៅលើផ្លូវជាតិមានលេខ១(មួយ)ខ្ទង់ ផ្លូវជាតិមានលេខ២(ពីរ)ខ្ទង់ ព្រមទាំងផ្លូវរថភ្លើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

អនុក្រឹត្យនេះ មិនមានវិសាលភាពគ្របដណ្តប់ទៅលើផ្លូវអភិវឌ្ឍទាំងឡាយនៅតាមបណ្តោយព្រំដែនដែលមិនមែនជាផ្លូវជាតិ ផ្លូវជាតិក្នុងដែនបម្រុងសត្វព្រៃនិងឧទ្យានជាតិ ផ្លូវជាតិក្នុងដែនបម្រុងរុក្ខា ផ្លូវលំជនបទ ផ្លូវជាតិអមប្រឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងទទួលខុសត្រូវដោយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកនិងឧតុនិយម និងផ្លូវជាតិផ្សេងៗទៀតដែលសាងសង់ដោយឃុំសង្កាត់ សហគមន៍ និងប្រជាពលរដ្ឋ។

**មាត្រា៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ៖

- ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង សំដៅដល់ចម្រៀកដីសងខាងអ័ក្សនៃផ្លូវជាតិនិងផ្លូវរថភ្លើង ដែលត្រូវបានអភិវឌ្ឍឬនឹងត្រូវអភិវឌ្ឍ ហើយត្រូវបានដាក់ឱ្យនៅក្រោមការគ្រប់គ្រងនិងការទទួលខុសត្រូវទាំងស្រុងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយបម្រុងទុកស្របតាមបទដ្ឋានបច្ចេកទេស ដែលមានប្រវែងពីអ័ក្សទៅតាមប្រភេទផ្លូវដូចមានចែងក្នុងមាត្រា៨និងមាត្រា៩នៃអនុក្រឹត្យនេះ

- ផ្លូវជាតិ ហៅកាត់ថា "ផ្លូវ" សំដៅដល់ទំហំផ្លូវទាំងមូល ដែលរួមមានថ្នល់ផ្លូវ រួមជាមួយជាយផ្លូវ ឬ ចិញ្ចើមផ្លូវ

- ផ្លូវរថភ្លើង សំដៅដល់ផ្លូវដែលកើតឡើងដោយការសាងសង់សម្រាប់ឱ្យរថភ្លើងធ្វើចរាចរណ៍ ដឹកជញ្ជូន គ្រប់ប្រភេទ រួមទាំងសំណង់សិល្បការ្យ និងបរិក្ខារផ្លូវរថភ្លើង

- ថ្នល់ផ្លូវ សំដៅដល់ផ្នែកមួយនៃផ្លូវទុកសម្រាប់យានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍

- ជាយផ្លូវ សំដៅដល់ផ្នែកសងខាងនៃថ្នល់ផ្លូវដែលនៅក្រៅទីប្រជុំជន ហើយអាចចតយានជំនិះ នៅទីនោះ បានក្នុងករណីចាំបាច់

- ចិញ្ចើមផ្លូវ សំដៅដល់ជាយផ្លូវនៅក្នុងទីប្រជុំជនដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ប៉ុន្តែមិន អាចចតយានជំនិះនៅទីនោះបានទេ

- ផ្លូវជាតិ សំដៅដល់៖

 ១- ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញ ឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស ។

 ២- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត ។

 ៣- ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ ។

 ៤- ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ ។

 ៥- ផ្លូវភ្ជាប់ចេញពីផ្លូវជាតិទៅកាន់តំបន់សំខាន់ៗជាអាទិ៍ កំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរ ច្រកទ្វារព្រំដែន និងតំបន់មានសក្តានុពលសេដ្ឋកិច្ច ផ្សេងៗទៀត ។

 ៦- ផ្លូវសំខាន់ៗរបស់ជាតិ មានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ ក្រសួងសាធារណការនិងដឹកជញ្ជូន ។

ផ្លូវជាតិ ត្រូវបានបែងចែកជា ២(ពីរ) កម្រិត៖

- ផ្លូវជាតិកម្រិត ១ សំដៅដល់ផ្លូវជាតិ ដែលតាងដោយលេខ ១(មួយ) ខ្ទង់
- ផ្លូវជាតិកម្រិត ២ សំដៅដល់ផ្លូវជាតិ ដែលតាងដោយលេខ ២(ពីរ) ខ្ទង់ ។

- ផ្លូវតំបន់ សំដៅដល់បណ្តាផ្លូវជាតិដែលតភ្ជាប់ជាមួយផ្លូវប្រទេសជិតខាងស្ថិតក្នុងតំបន់ និងត្រូវបាន កំណត់ជាលក្ខណៈអន្តរជាតិ

- ផ្លូវសាធារណៈ សំដៅដល់ផ្លូវសម្រាប់បើកឱ្យធ្វើចរាចរណ៍ទូទៅជាសាធារណៈ

- ផ្លូវឯកជន សំដៅដល់ផ្លូវកសាងដោយឯកជនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ ហើយដែលបាន សាងសង់ ឬជួសជុលដោយឯកជនតាមកិច្ចសន្យាជាមួយរដ្ឋ

- សំណង់សិល្បការ្យ សំដៅដល់ ស្ពាន លូ ប្រព័ន្ធបង្ហូរទឹក អាងស្តុកទឹកបម្រើឱ្យផ្លូវជាតិ ផ្លូវរថភ្លើង និងសំណង់រូបវន្តផ្សេងៗទៀតដែលផ្តល់នូវសុវត្ថិភាព និងប្រសិទ្ធភាព ស្ថិរភាពនៃផ្លូវជាតិ និងផ្លូវរថភ្លើង

- បរិក្ខារផ្លូវជាតិ ផ្លូវរថភ្លើង សំដៅដល់ របង របាំងការពារ ផ្ទាំង និងស្លាកសញ្ញា ភ្លើងបំភ្លឺ ភ្លើងស្តុប កន្លែងសម្រាក ទីចំណត ស្ថានីយរថភ្លើង ព្រមទាំងសម្ភារៈនិងសំណង់ផ្សេងៗទៀត ដែលមានស្ថិតនៅក្បែរ ឬលើ ផ្លូវជាតិនិងផ្លូវរថភ្លើង ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ ឬបម្រើផលប្រយោជន៍ ផ្លូវជាតិ និងផ្លូវរថភ្លើង

- ការអភិវឌ្ឍផ្លូវជាតិ ផ្លូវរថភ្លើង សំដៅដល់ការស្ថាបនា ការស្តារឡើងវិញ និងការកែលម្អផ្លូវជាតិ ផ្លូវរថភ្លើង ដោយមិនរាប់បញ្ចូលការថែទាំផ្លូវជាតិនិងផ្លូវរថភ្លើងឡើយ
- ទីប្រជុំជន សំដៅដល់ទីកន្លែងដែលមានអគារឬគេហដ្ឋានសង់ជិតៗគ្នា ហើយផ្លូវចេញឬចូលនៅទីនោះមានដាក់ផ្លាកសញ្ញាឈ្មោះទីប្រជុំជន ។

## ជំពូកទី២
## ការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង

**មាត្រា៥.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវជាតិ និងផ្លូវរថភ្លើង ក្នុងការធ្វើផែនការ ការសិក្សាគម្រោងប្លង់អភិវឌ្ឍផ្លូវជាតិនិងផ្លូវរថភ្លើង ឬផ្តល់សេវាកម្មផ្សេងៗទៀតដែលពាក់ព័ន្ធនឹងផ្លូវជាតិនិងផ្លូវរថភ្លើង ដើម្បីបម្រើផលប្រយោជន៍អ្នកប្រើប្រាស់ផ្លូវជាតិ និងផ្លូវរថភ្លើងឱ្យមានប្រសិទ្ធភាពល្អ ។

**មាត្រា៦.-**

ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងការគ្រប់គ្រងដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង ដោយផ្អែកលើគោលការណ៍ច្បាប់ជាធរមាន ។

## ជំពូកទី៣
## ការកំណត់ដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង
## សម្រាប់បម្រើការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

**មាត្រា៧.-**

ដីចំណីនៅតាមបណ្តោយផ្លូវជាតិនិងផ្លូវរថភ្លើង គឺជាសម្បត្តិសាធារណៈរបស់រដ្ឋ ស្របតាមមាត្រា១៥ នៃច្បាប់ភូមិបាល ។

**មាត្រា៨.-**

ដីចំណីផ្លូវ ត្រូវបានកំណត់សម្រាប់បម្រើការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចតទៅ៖

- ផ្លូវជាតិកម្រិត១ : តាងដោយលេខ១(មួយ)ខ្ទង់ ដីចំណីផ្លូវមានប្រវែង៣០(សាមសិប)ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ
- ផ្លូវជាតិកម្រិត២ : តាងដោយលេខ២(ពីរ)ខ្ទង់ ដីចំណីផ្លូវមានប្រវែង២៥(ម្ភៃប្រាំ)ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ។

ចំពោះដីចំណីផ្លូវជាតិនៃប្រភេទទាំង២(ពីរ)ខាងលើដែលឆ្លងកាត់រាជធានីឬក្រុងនៃខេត្តឬទីប្រជុំជន នឹងមានកំណត់ដោយឡែកអំពីដីចំណីផ្លូវជាតិរបស់រាជធានី និងក្រុងនៃខេត្ត ឬទីប្រជុំជន ។

**មាត្រា៩.-**

ដីចំណីផ្លូវរថភ្លើង ត្រូវបានកំណត់សម្រាប់បម្រើការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចតទៅ៖

- ដីចំណីផ្លូវរថភ្លើងក្រៅរាជធានី ក្រុង និងទីប្រជុំជន ត្រូវមានប្រវែង៣០(សាមសិប)ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ
- ដីចំណីផ្លូវរថភ្លើងដែលស្ថិតនៅក្នុងតំបន់ព្រៃភ្នំ ដែលមានផ្លូវមៀវលធ្លាក់ឬតំបន់ព្រៃខ្ពស់ ត្រូវមានប្រវែង១០០(មួយរយ)ម៉ែត្រពីសងខាងអ័ក្សផ្លូវ
- ដោយឡែកចំពោះដីបរិវេណស្ថានីយ៍រថភ្លើង ត្រូវអនុលោមតាមប្លង់ដែលមានជាធរមាន ។

ចំពោះដីចំណីផ្លូវរថភ្លើង ដែលឆ្លងកាត់រាជធានីឬក្រុងនៃខេត្តឬទីប្រជុំជន នឹងមានកំណត់ដោយឡែកអំពីដី ចំណីផ្លូវរថភ្លើងរបស់រាជធានី និងក្រុងនៃខេត្ត ឬទីប្រជុំជន ។

**មាត្រា១០.-**

ការកំណត់ដីចំណីផ្លូវខាងលើត្រូវធ្វើឡើងតែម្តងគត់ ទោះបីត្រូវអភិវឌ្ឍផ្លូវថែមទៀតក៏ដោយ ការកំណត់ដីចំណីផ្លូវត្រូវរក្សានៅដដែល ។

**មាត្រា១១.-**

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ មិនត្រូវអនុញ្ញាតឱ្យសាងសង់សំណង់ ការដាំដំណាំផ្សេងៗ នៅតាមដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើងឡើយ ។

ការដាំដុះដំណាំមួយចំនួនមានលក្ខណៈអាស្រ័យផល ត្រូវមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលនិងត្រូវមានកិច្ចសន្យាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ។ ពេលត្រូវការអភិវឌ្ឍផ្លូវរដ្ឋមិនទទួលខុសត្រូវទូទាត់សំណងឡើយ ។

**មាត្រា១២.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវចេញប្រកាសឬសេចក្តីណែនាំ ដើម្បីកំណត់ការប្រើប្រាស់ដីចំណីផ្លូវជាតិ និងផ្លូវរថភ្លើង សម្រាប់ជាប្រយោជន៍សាធារណៈនិងឯកជន ជាអាទិ៍ ការដឹកកប់បណ្តាញ ខ្សែកាបអុបទិក បំពង់ទឹកស្អាត ការបោះបង្គោលអគ្គិសនី ការបោះបង្គោលអ៊ុបទិក ការបោះបង្គោលផ្សាយពាណិជ្ជកម្ម និងការប្រើប្រាស់ផ្សេងៗទៀត ទាក់ទងនឹងដីចំណីផ្លូវជាតិនិងផ្លូវរថភ្លើង ។

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវធ្វើការសិក្សាដើម្បីដាក់តាំងផ្ទាំងរូបភាព ស្តីពីការកំណត់ដីចំណីផ្លូវនៅតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង ជំនួសការបោះបង្គោលដីចំណីផ្លូវ ។

## ជំពូកទី៤

## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៣.-**

រដ្ឋធ្វើការទូទាត់សំណង ដោយអនុលោមតាមគោលនយោបាយនៃការតាំងលំនៅថ្មីនិងស្របតាមមាត្រា១៤៨នៃច្បាប់ភូមិបាល ចំពោះកម្មសិទ្ធិករស្របច្បាប់លើក្បាលដីដែលត្រូវបានកំណត់ជាដី ដូចមានចែងក្នុងមាត្រា៨និងមាត្រា៩នៃអនុក្រឹត្យនេះ សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការដែលបានកំណត់មុនអនុក្រឹត្យនេះ ព្រមទាំងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៤.–**

ការទូទាត់ផលប៉ះពាល់ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ ដំណាំផ្សេងៗ ព្រមទាំងរបងនិងសំណង់ទាំងឡាយ ដូចជា ទំនប់ទឹក ប្រឡាយទឹក ដីស្រែ ដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**មាត្រា១៥.–**

រាល់ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ដែលមានចែងក្នុងមាត្រា៨និងមាត្រា៩នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៦.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៧.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ